ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ : ១៥០
ចុះថ្ងៃទី ២៤-០១-២០០៧
សាលដីកា
លេខ : ៦២ "ខ"
ចុះថ្ងៃទី ០១-០៦-២០០៧

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ០១-០៦-២០០៧ ដោយមានសមាសភាពដូចខាងក្រោម:

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជី</u>**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ: ១៥០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៧ ដែលមាន:

- **ជនជាប់ចោទឈ្មោះ** [redacted] ប្រុស ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ កើត និងរស់នៅភូមិព្រែករាំង [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ។

**<u>ត្រូវជាប់ចោទពីបទ:</u>** ប៉ុនប៉ងធ្វើមនុស្សឃាត ប្រព្រឹត្តនៅស្រុកតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០០៦ ។

- **ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] យ៉ាត ភេទប្រុស អាយុ ៤៣ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិព្រែករាំង ឃុំកំពង់សំណាញ់ ស្រុកតាខ្មៅ ខេត្តកណ្តាល ។

- តាមពាក្យបណ្តឹងឧទ្ធរណ៍លេខ ០១ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧ របស់លោកព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តកណ្តាល ប្តឹងមិនសុខចិត្តនឹងការសម្រេចមិនឃុំខ្លួនឈ្មោះ [redacted] ប្រុស នៅក្នុងកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៦ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកណ្តាល ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

## ដំណើររឿងមានដូចតទៅ:

តាមពាក្យបណ្ដឹងចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] យ៉ាត សុំប្ដឹងពីឈ្មោះ[redacted] ប្រុស និងបក្សពួកដោយហេតុថា កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០០៦ វេលាម៉ោង ២១ នៅចំណុចក្រុម ៨ មុខផ្ទះលេខ ១២៨ ខាងកើតស្ថានីយ៍ព្រែករាំងទី ១ ឈ្មោះ [redacted] ប្រុស និងបក្សពួក ២នាក់ ទៀត បានពួនស្ទាក់វាយខ្លួនដោយមិនដឹងខ្លួនមិនដឹងរឿងអ្វី ខ្លួនត្រូវបែកក្បាល បាក់ក្ដោងច្រមុះ បាក់ធ្មេញ និងត្រូវពេញទាំងខ្លួន។ ពេលខ្លួនជិះម៉ូតូទៅផ្ទះបងប្អូន ឃើញពួកវាកំពុងផឹកស្រា ពួកវាបានជេរប្រមាថខ្លួនរកសម្លាប់ មួយសន្ទុះខ្លួនត្រឡប់មកវិញ ពួកវាក៏ចេញមកស្ទាក់វាយធ្វើឱ្យខ្លួនមានរបួសជាទម្ងន់។

**បានឃើញ ការសម្រេចមិនឃុំខ្លួនរបស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកណ្ដាល ដែលបានសម្រេចសេចក្ដីដូចខាងក្រោម:**

មិនឃុំខ្លួនឈ្មោះ [redacted] ប្រុស ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ កើត និងរស់នៅភូមិ[redacted] ស្រុកតាខ្មៅ ខេត្តកណ្ដាល ឪពុកឈ្មោះ[redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ។

- បានឃើញ ពាក្យបណ្ដឹងឧទ្ធរណ៍លេខ ០១ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧ របស់លោកព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តកណ្ដាល ប្ដឹងមិនសុខចិត្តនឹងការសម្រេចមិនឃុំខ្លួនឈ្មោះ [redacted] ប្រុស នៅក្នុងកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៦ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកណ្ដាល ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។
- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយជនជាប់ចោទឈ្មោះ[redacted] ប្រុស បានឆ្លើយនៅតុលាការខេតកណ្ដាល។

ប្រធានក្រុមប្រឹក្សាអានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted] យ៉ាត បានឆ្លើយនៅតុលាការខេតកណ្ដាល។

## សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្នុងអង្គហេតុនេះតំណាងអយ្យការបានចោទប្រកាន់ឈ្មោះ [redacted] ប្រុស ពីបទ ប៉ុនប៉ងធ្វើមនុស្សឃាត នៅពេលចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចមិនឱ្យឃុំខ្លួន ពេលនោះ ព្រះរាជអាជ្ញាមិនបានបានទទួលដំណឹងទេ ទើបតែទទួលដំណឹងនៅលើដីកាជូនរឿងទៅពិនិត្យមូល ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៦។ ដូច្នេះ ព្រះរាជអាជ្ញាប្ដឹងឧទ្ធរណ៍នេះ ស្ថិតក្នុងកំណត់ច្បាប់ ដូចនេះ តំណាងមហាអយ្យការសុំសន្និដ្ឋាន: -

១- ទទួលបណ្ដឹងឧទ្ធរណ៍ក្នុងចំណោរ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៧ របស់លោក[redacted] វុទ្ធី ព្រះរាជអាជ្ញា ដែលចម្លងចេញក្នុងសេចក្ដីចម្លងប្ដឹងតវ៉ា ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២- បដិសេធការសម្រេចមិនឃុំខ្លួនឈ្មោះ [redacted] ប្រុស ភេទប្រុស អាយុ ២៥ឆ្នាំ នៅភូមិ [redacted] សំណាញ់ ស្រុកតាខ្មៅ ខេត្តកណ្តាល នៅក្នុងកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៦ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកណ្តាល ទុកជាអសាបង់ ។

- ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

**សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថាៈ**

១- បណ្តឹងឧទ្ធរណ៍លេខ ០១ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧ របស់លោកព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តកណ្តាល ធ្វើឡើងផ្ទុយនឹងទម្រង់ច្បាប់ គឺបញ្ញត្តិនៃមាត្រា ៧៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍មិនអាចទទួលជំនុំជម្រះបានឡើយ ។

២- តាមកំណត់ហេតុសួរចម្លើយចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៦ ចៅក្រមស៊ើបអង្កេតបានសម្រេចមិនឃុំខ្លួនជនជាប់ចោទ រួចហើយបានបញ្ជូនតាមដីកាបញ្ជូនរឿងមូលទៅពិនិត្យលេខ ៧៣៤ ដកពម ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦ ជូនព្រះរាជអាជ្ញាដើម្បីពិនិត្យអំពីការសម្រេចនោះ តែព្រះរាជអាជ្ញាមិនប្តឹងឧទ្ធរណ៍នឹងការសម្រេចរបស់ចៅក្រមស៊ើបអង្កេត បែរជាចារបញ្ជាឱ្យចៅក្រមស៊ើបអង្កេតចេញដីកាចាប់ខ្លួនជនសង្ស័យ និងសុំឱ្យឃុំខ្លួនទៅវិញ ។ តបនឹងចំណារនេះ ចៅក្រមស៊ើបអង្កេតបានសម្រេចបញ្ជូនដីកាបញ្ជូនរឿងទៅពិនិត្យលេខ ២០៥ ដកដព ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៧ ទៅជូនព្រះរាជអាជ្ញា ដោយបញ្ជាក់ពីការសម្រេចមិនឃុំខ្លួនជនជាប់ចោទរបស់ខ្លួនវិញ ទើបព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ ។ ជាគោលការណ៍តាមបញ្ញត្តិមាត្រា ៧៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាត្រូវប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចមិនឃុំខ្លួនជនជាប់ចោទនៅក្នុងកំណត់ហេតុសួរចម្លើយចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៦ របស់ចៅក្រមស៊ើបអង្កេតក្នុងរយៈ ៥ថ្ងៃ គត់ ។

ដូច្នេះ គួរចំណាយរឿងក្តីលេខ ១៥០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៧ របស់សាលាឧទ្ធរណ៍ ចេញពីបញ្ជីជំនុំជម្រះសាលាឧទ្ធរណ៍ ហើយបញ្ជូនទៅតុលាការថ្នាក់ក្រោមវិញ ដើម្បីចាត់ការតាមនីតិវិធី និងដាក់ជំនុំជម្រះតាមច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១- មិនទទួលជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍លេខ ០១ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧ របស់លោកព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តកណ្តាល ដោយផ្ទុយនឹងទម្រង់ច្បាប់ ។

២- ចំណាយរឿងក្តីព្រហ្មទណ្ឌលេខ ១៥០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៧ ចេញពីបញ្ជីជំនុំជម្រះសាលាឧទ្ធរណ៍ ។

៣- បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ១៥០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៧ របស់សាលាឧទ្ធរណ៍ទៅតុលាការខេត្តវិញ ដើម្បីចាត់ការតាមនីតិវិធី និងដាក់ជំនុំជម្រះតាមច្បាប់ ។

៤- សាលដីកានេះមានអានុភាពអនុវត្តភ្លាមៗ ទោះជាមានបណ្តឹងសាទុក្ខក៏ដោយ ។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ កំបាំងមុខតួក្តី បើកផ្លូវសាទុក្ខតាមកំណត់ច្បាប់ ។

សេចក្តីនេះព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែងជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ៗ

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា: |
| [redacted] | [redacted] | [redacted] |

---

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី 27 ខែ 12 ឆ្នាំ២០០៧

ក្រឡាបញ្ជី